# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៥៥ សសរ. កសក

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិនិងអនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ២២០ ប្រក.កសក.ប ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត
- បានឃើញសេចក្តីសម្រេចលេខ៣២៣ សសរ កសក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១.-**

ត្រូវបានធ្វើការកែសម្រួលសមាសភាពគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ទី សុគន្ធ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២.ឯកឧត្តម **គង់ ចាន់** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣.លោកជំទាវ **ម៉ុម ថានី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤.លោកឧកញ៉ា **លឹម ហេង** | អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា | អនុប្រធាន |
| ៥.ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម | | អនុប្រធានអចិន្ត្រៃយ៍ |
| ៦.លោក **ចាន់ ហេង** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧.លោកស្រី **កាំង យីម** | អនុប្រធានរដ្ឋបាលជលផល | សមាជិកា |
| ៨.លោក **ហ៊ីម អូន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៩.លោក **ស្រ៊ុន សុខុម** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ១០.លោក **អ៊ុង សំអាត** | អនុប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ១១.លោកស្រី **សេង មុំ** | សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិកា |
| ១២.លោក **សួន សេរី** | នាយកសាលាជាតិកសិកម្មកំពង់ចាម | សមាជិក |
| ១៣. លោក **ហុង ណារិត** | ប្រធានមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម | សមាជិក |
| ១៤.លោក **ស្រី ខុឡា** | ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ១៥.លោក **ទី ចាន់ណា** | ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១៦.លោក **ឡាំ ច័ន្ទណារិទ្ធិ** | នាយករងសាលាជាតិកសិកម្មព្រែកលៀប | សមាជិក |
| ១៧.លោកស្រី **សាខន សុផានី** | នាយិការងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិកា |
| ១៨.លោកស្រី **អ៊ុក សាទិន** | អនុប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល | សមាជិកា |
| ១៩.លោកស្រី **សុខ សុទ្ធាវី** | ប្រធានរដ្ឋបាលសភាពាណិជ្ជកម្មកម្ពុជា | សមាជិកា |
| ២០.លោក **ម៉ៅ មិនា** | ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | លេខាធិការ។ |

## ប្រការ២.-

គណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គាំទ្រ និងសម្របសម្រួលសកម្មភាពនិងទំនាក់ទំនងរវាងការស្រាវជ្រាវ ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលកសិកម្ម
- គាំទ្រ ណែនាំ និងសម្របសម្រួលការប្រតិបត្តិកម្មវិធី គម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅកម្ពុជា
- កៀរគរធនធាន និងថវិកាគាំទ្រដល់កម្មវិធី គម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅកម្ពុជា
- ណែនាំ ពិនិត្យ និងសម្រេចលើការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មី កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស ឯកសារ សម្ភារ មធ្យោបាយ និងវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ និងសម្រេចលើរបាយការណ៍ ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីគម្រោង និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានានៅកម្ពុជា
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

## ប្រការ៣.-

ត្រូវបានធ្វើការកែសម្រួលសមាសភាពអនុគណៈកម្មាធិការបច្ចេកទេសកសិកម្ម ដែលស្ថិតក្រោមគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់ការផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **គង់ ចាន់** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២.លោកឧកញ៉ា **លឹម ហេង** | អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា | អនុប្រធាន |
| ៣.ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម | | អនុប្រធានអចិន្ត្រៃយ៍ |
| ៤.លោក **ម៉ាក់ សឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៥.លោក **ខិន ឆាយ** | ប្រធាននាយកដ្ឋានដំណាំស្រូវនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៦.លោក **មាស សុទ្ធី** | នាយកផ្នែកស្រាវជ្រាវនិងផ្សព្វផ្សាយនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ៧.លោក **ម៉ក់ ម៉ូនី** | អនុប្រធាននាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ៨.លោក **ឃុន ភក្តដា** | អនុប្រធាននាយកដ្ឋានកៅស៊ូនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៩. លោក **ឈួន គីមឈា** | អនុប្រធាននាយកដ្ឋាននៃរដ្ឋបាលជលផល | សមាជិក |
| ១០.លោក **ទ៉ា វ៉េងហេង** | នាយករងសាលាជាតិកសិកម្មកំពង់ចាម | សមាជិក |
| ១១. លោក **ប៉ុល ចាន់ធី** | ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាននៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១២. លោក **សេដ្ឋ សុជីវន្ត** | ប្រធានដេប៉ាតឺម៉ង់ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ជនបទនៃសាលាជាតិកសិកម្មព្រែកលៀប | សមាជិក |
| ១៣. លោក **គា ឆា** | ប្រធានការិយាល័យនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល | សមាជិក |
| ១៤. លោក **នុព សុធា** | ប្រធានការិយាល័យផ្សព្វផ្សាយនិងទំនាក់ទំនងសាធារណៈនៃរដ្ឋបាលព្រៃឈើ | សមាជិក |
| ១៥.លោក **សាម៉េង កែវមុនីន** | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម | លេខាធិការ។ |

## ប្រការ៤.-

អនុគណៈកម្មាធិការបច្ចេកទេសកសិកម្មមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ សម្របសម្រួលកំណត់កម្មវត្ថុនិងប្រធានបទស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗសម្រាប់ផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ សម្របសម្រួលកំណត់កម្មវិធីអភិវឌ្ឍធនធានមនុស្សសម្រាប់ផ្សព្វផ្សាយកសិកម្មដែលរួមមាន កម្មវិធីសិក្សានិងការបណ្តុះបណ្តាលមន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ សម្របសម្រួលកំណត់គោលការណ៍ណែនាំ ប្រធានបទ កម្មវត្ថុ ឯកសារ សម្ភារ និងសារផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ សម្របសម្រួលកំណត់មធ្យោបាយ និងវិធីសាស្ត្រសេវាផ្សព្វផ្សាយកសិកម្ម
- ពិនិត្យ តាមដានវាយតម្លៃ និងធ្វើរបាយការណ៍ពីសកម្មភាពកម្មវិធីនិងគម្រោងផ្សព្វផ្សាយកសិកម្មនានានៅកម្ពុជា ដើម្បីដាក់ជូនគណៈកម្មាធិការប្រឹក្សាយោបល់សម្រាប់កាផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិពិនិត្យនិងសម្រេច
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៥.-**

សមាជិកគណៈកម្មាធិការ និងអនុគណៈកម្មាធិការខាងលើ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៦.-**

សេចក្តីសម្រេចលេខ ៣២៣ សសរ កសក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ នាយកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នាយកសាលាជាតិកសិកម្មព្រែកលៀប នាយកសាលាជាតិកសិកម្មកំពង់ចាម ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មរាជធានីខេត្ត និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ